ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ស្ថានឯកអគ្គរាជទូតកម្ពុជា
ប្រចាំប្រទេសជប៉ុន

# សេចក្តីប្រកាសព័ត៌មាន

## ស្ថានឯកអគ្គរាជទូតកម្ពុជា និងរដ្ឋបាលក្រុងតូក្យូ ស្វែងរកនូវកិច្ចសហប្រតិបត្តិការកម្រិតទីក្រុង

នៅថ្ងៃទី៨ ខែមករា ឆ្នាំ២០២៦ ឯកឧត្តម **ជុំ សុន្ទរី** ឯកអគ្គរាជទូតតែងតាំងនៃព្រះរាជាណាចក្រកម្ពុជាប្រចាំប្រទេសជប៉ុន បានអញ្ជើញទទួលជួបមន្ត្រីជាន់ខ្ពស់នៃរដ្ឋបាលក្រុងតូក្យូ ដឹកនាំដោយលោក KUWABARA Atsushi ទីប្រឹក្សាពិសេសរបស់អភិបាលក្រុងតូក្យូសម្រាប់កិច្ចការអន្តរជាតិ។ ក្នុងជំនួបនោះ ភាគីទាំងពីរបានផ្លាស់ប្តូរទស្សនៈលើការពង្រឹងកិច្ចសហប្រតិបត្តិការរវាងកម្ពុជានិងតូក្យូនៅកម្រិតទីក្រុង។ ឯកឧត្តមឯកអគ្គរាជទូតបានសម្តែងការកោតសរសើរចំពោះការដឹកនាំរបស់រដ្ឋបាលក្រុងតូក្យូ ក្នុងការលើកកម្ពស់ការអភិវឌ្ឍទីក្រុងប្រកបដោយចីរភាព និងស្វាគមន៍ការចូលរួមជាបន្តបន្ទាប់ដើម្បីបង្កើនមិត្តភាព និងកិច្ចសហប្រតិបត្តិការរវាងកម្ពុជានិងជប៉ុន។

ឯកឧត្តមឯកអគ្គរាជទូត បានបង្ហាញពីចំណាប់អារម្មណ៍យ៉ាងខ្លាំងរបស់កម្ពុជាក្នុងការចូលរួមជាមួយបណ្តាញទីក្រុងសកលសម្រាប់ចីរភាព(G-NETS) ដែលជាវេទិកាបំពេញបន្ថែមសម្រាប់កិច្ចសហប្រតិបត្តិការ និងបានកត់សម្គាល់ពីការចូលរួមដ៏មានសក្តានុពលនៃទីក្រុងធំៗរបស់កម្ពុជាដូចជា ភ្នំពេញ សៀមរាប និងព្រះសីហនុ។ ភាគីទាំងពីរបានទទួលស្គាល់ពីគុណតម្លៃនៃកិច្ចសហប្រតិបត្តិការក្នុងវិស័យនានា រួមមាន ចីរភាព ភាពធន់នឹងអាកាសធាតុ ចល័តភាព និងការអភិវឌ្ឍទីក្រុងឆ្លាតវៃ ព្រមទាំងបានបង្ហាញពីការត្រៀមខ្លួនរួចជាស្រេច ដើម្បីរក្សាការសម្របសម្រួលយ៉ាងជិតស្និទ្ធ រួមទាំងក្នុងបរិបទនៃការចូលរួមនាពេលខាងមុខរបស់កម្ពុជា នៅក្នុងកិច្ចប្រជុំកំពូល G-NETS លើកទី៣ នៅខែមេសា ឆ្នាំ២០២៦ ដែលជប៉ុនជាម្ចាស់ផ្ទះ ដើម្បីជំរុញកិច្ចសហប្រតិបត្តិការរវាងទីក្រុងនិងទីក្រុងដែលមានលក្ខណៈជាក់ស្តែង និងផ្តល់ប្រយោជន៍ទៅវិញទៅមក ។

ភាគីទាំងពីរបានគូសបញ្ជាក់ពីសារៈសំខាន់នៃការរក្សាការសម្របសម្រួល និងទំនាក់ទំនងយ៉ាងជិតស្និទ្ធ ដើម្បីជំរុញកិច្ចសហប្រតិបត្តិការជាក់ស្តែង និងមានប្រយោជន៍ទៅវិញទៅមក។ កិច្ចប្រជុំនេះបានឆ្លុះបញ្ចាំងពីការប្តេជ្ញាចិត្តរួមគ្នារបស់កម្ពុជានិងជប៉ុន ក្នុងការលើកកម្ពស់ចំណងមិត្តភាពរវាងប្រជាជននិងប្រជាជន និងគាំទ្រដល់ភាពជាដៃគូយុទ្ធសាស្ត្រដ៏ទូលំទូលាយរវាងកម្ពុជានិងជប៉ុន តាមរយៈការពង្រឹងកិច្ចសហប្រតិបត្តិការនៅកម្រិតមូលដ្ឋាន និងទីក្រុង។

ថ្ងៃព្រហស្បតិ៍ ៥រោច ខែបុស្ស ឆ្នាំម្សាញ់ សប្តស័ក ព.ស ២៥៦៩
តូក្យូ ថ្ងៃទី៨ ខែមករា ឆ្នាំ២០២៦

8-6-9 AKASAKA, MINATO-KU, TOKYO 107-0052
Tel : +81 3-5412-8521 Fax: +81 3-5412-8526
Email: camemb.jpn@mfaic.gov.kh